**BMI0040**

# សម្ភាសជាមួយឈ្មោះ ជៀប សុខ ភេទ ស្រី អាយុ៥៣ ឆ្នាំ

មុខងារនៅសម័យខ្មែរក្រហមៈ ពេទ្យ

មុខងារបច្ចុប្បន្នៈ ធ្វើស្រែ

មានស្រុកកំណើតនៅ ភូមិអាគ្រាច ឃុំព្រៃឈរ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង

សព្វថ្ងៃរស់នៅភូមិកណ្តាល ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ឡុង ដានី

០០:៤៧:២១

សរុបៈ ២៧ ទំព័រ

ដានី : ដំបូងខ្ញុំចង់ស្គាល់ឈ្មោះមីង មីងឈ្មោះអីដែរ?

សុខ : ឈ្មោះ ជៀប សុខ!

ដានី : ឈ្មោះពីដើមក៏ឈ្មោះ ជៀប សុខ អញ្ចឹងដែរ?

សុខ : ចា៎! ឈ្មោះពីកំណើត ។

ដានី : មីងអត់ដែលមានដូរឈ្មោះទេ?

សុខ : អត់ទេ!

ដានី : មីងអាយុប៉ុន្មានហើយសព្វថ្ងៃ?

សុខ : ខ្ញុំអាយុ៥៣ហើយ ។

ដានី : មីងរស់នៅក្នុងភូមិអីដែលសព្វថ្ងៃ?

សុខ : ភូមិកណ្តាល ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ។

ដានី : ឃុំម៉ាឡៃ ស្រុកម៉ាឡៃនោះ?

សុខ : ចា៎!

ដានី : បាទ! គ្រួសារមីងឈ្មោះអីដែរ?

សុខ : ឈ្មោះ វ៉ែន សំអាត ។

ដានី : គាត់អាយុប៉ុន្មានដែរ?

សុខ : អាយុ៥០ឆ្នាំ ។

ដានី : អាយុ៥០ឆ្នាំ អាយុតិចជាងមីង៣ឆ្នាំអញ្ចឹង?

សុខ : ចា៎!

ដានី : មានកូនចៅទាំងអស់ប៉ុន្មាននាក់ដែរ?

សុខ : ខ្ញុំមានកូន២នាក់ ប្រុស១ ស្រី១ ។

ដានី : កូនតែ២នាក់ទេ?

សុខ : ចា៎!

ដានី : កូនតិច?

សុខ : ខ្ញុំក្រណាស់ខ្ញុំយកកូនច្រើនអត់មានលុយឲ្យរៀនទេ ។

ដានី : អ្ហូ!អញ្ចឹង អាយុប៉ុន្មានហើយកូន?

សុខ : អាមួយ១៩ឆ្នាំ អាមួយទៀត១១ឆ្នាំ ។

ដានី : បាទ!ចុះមីងសព្វថ្ងៃប្រកបរបររកស៊ីអីដែរ?

សុខ : មានធ្វើអីទេកូន ធ្វើប៉ិកប៉ក់ៗនៅផ្ទះ ។

ដានី : ធ្វើអីទៅប៉ិកប៉ក់ៗហ្នឹង?

សុខ : ប៉ិកប៉ក់ធ្វើតូចតាចៗទៅ ធ្វើស៊ីឈ្នួលគេហ្នឹង ធ្វើស្រែអីបន្តិចៗទៅ គ្មានអីជាដុំដុំកំភួនទេ គ្រាន់តែចិញ្ចឹម គ្រាន់តែរស់គេឯងទៅ ។

ដានី : បាទ!

សុខ : ក្រណាស់រកល្ងាចខ្វះព្រឹក រកព្រឹកខ្វះល្ងាចទៅ ។

ដានី : បាទ!មីងស្រុកកំណើតមីងនៅណា?

សុខ : នៅភូមិអាគ្រាច ឃុំព្រៃឈរ អាហ្នឹងពីដើមពីដែកនោះ ប៉ុន្តែឥឡូវមិនដឹងគេដាក់ប្រែប្រួលម៉េចខ្ញុំស្គាល់ទេ ។

ដានី : ភូមិអីគេ?

សុខ : ភូមិអាគ្រាច ឃុំព្រៃឈរ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។

ដានី : ចុះឪពុកម្ដាយមីងគាត់ឈ្មោះអីដែរ?

សុខ : ស្លាប់អស់ហើយ ឪពុកម្ដាយខ្ញុំអត់មាននៅទេ ស្លាប់មិនស្គាល់មុខ ។

ដានី : បាទ!គាត់ឈ្មោះអីទៅ?

សុខ : ឪពុកឈ្មោះ ខាន់ ម្ដាយឈ្មោះ ស្រ៊ុន ។

ដានី : គាត់ខូចតាំងពីអង្កាល់?

សុខ : ខ្ញុំអត់ចាំដែរពូ ព្រោះខ្ញុំរត់ម៉ោ របូនម៉ោតាមគេតាមឯងនៅមិត្តនារីនោះ ។

ដានី ៖ អ្ហូ!មីងនៅមានបងប្អូនបង្កើតប៉ុន្មាននាក់ដែរ?

សុខ ៖ បងប្អូនបង្កើតនៅសល់៤នាក់ ។

ដានី ៖ អញ្ចឹងទាំងអស់ប៉ុន្មាន?

សុខ ៖ ៥នាក់ ទៅមិនស្គាល់បងប្អូនទៀត ទៅអត់មានស្គាល់បងប្អូនទៅទាល់តែគេចាប់ដៃដាក់ ហ្នឹង អត់ស្គាល់ទេ ឪនៅរស់ ឆ្នាំណានោះអត់ស្គាល់ដែរ ទាល់តែគេចាប់ដៃដាក់ដែរ ដល់ក្រោយម៉ោគាត់ស្លាប់ទៅ គាត់ឈឺស្លាប់ទៅ ។

ដានី ៖ ៥នាក់ ស្លាប់១នាក់ នៅសល់៤នាក់?

សុខ ៖ ចាំ!ស្លាប់ប្រុស១នាក់ នៅសល់ប្រុស១នាក់ ស្រី៣នាក់ កូនចៅអ្នកក្រីក្រដែរហ្នឹងពូ អើយ! អ្នកស្រុកស្រែយើងឲ្យតែមានអង្ករហូបហ្នឹងអរគុណហើយ ។

ដានី ៖ បាទ!ចុះមីងកាលពីក្មេងៗមីងបានរៀនសូត្រដល់ថ្នាក់ណាដែរ?

សុខ ៖ ថ្នាក់ទី១០ពីសង្គមនោះ ហើយភ្លេចអស់ហើយរៀនៗរវល់តែរត់ គ្រាប់ផ្លោងចេះ មិនមែនគ្រាប់ផ្លោងទេ កាលនោះសម័យយន្តហោះទំលាក់ ។

ដានី ៖ ថ្នាក់ទី១០?

សុខ ៖ ចាំ!ហើយខានរៀនរហូតម៉ោ ។

ដានី ៖ ហើយឈប់រៀនឆ្នាំណា?

សុខ ៖ ឈប់រហូតម៉ោ ឈប់កាលយើងរៀនចូលព្រៃហ្នឹង យើងគេបង្កើតរៀនទៅ យើងរៀន ប៉ុនមើលអក្សរដាច់តិចតួចហ្នឹង មានអីត្រូវចេះចាំទេ ។

ដានី ៖ បាទ!ចុះមីងអ៊ីដូចថាឈប់រៀនហើយ យើងចូល?

សុខ ៖ ចូលនៅក្នុងអង្គភាពទៅ នៅក្នុងគ្រួសារគេអ្នកមានៗគ្រួសារអីហ្នឹងយើងនៅជាមួយគេ ទៅ នៅជាមួយមេភូមិអីហ្នឹងនៅជិតៗគ្នាអញ្ចឹងណាំ ។

ដានី ៖ នៅផ្ទះជិតៗគ្នា?

សុខ ៖ ចាំ!ស្គាល់គ្នាតាំងពីដើម ។

ដានី ៖ អញ្ចឹងគាត់នៅព្រៃវែងដែរ?

សុខ ៖ មិននៅទេ!ប៉ុនដូចយើងរត់ទៅអញ្ចឹង យើងស្គាល់គ្នាទៅណាំ ។

ដានី ៖ អ្ហូ!

សុខ ៖ ចេះតែរាប់ៗគ្នាទៅ ។

ដានី ៖ បាទ!ចុះមីងអ៊ីកាលពីឆ្នាំ មីងឈប់រៀនហើយ មីងចេញពីផ្ទះឆ្នាំណា?

សុខ ៖ ខ្ញុំចេញឆ្នាំ៧៥ ។

ដានី ៖ ឆ្នាំ៧៥?

សុខ ៖ ចាំ!តែចេញម៉ោដូចថាយើងមិនចេញដាច់ម៉ែឪទេ ដូចថាយើងចេញម៉ោនៅក្បែរៗមន្ទីរ ឃុំអីហ្នឹង ។

ដានី ៖ បាទ!ធ្វើអីទៅកាលហ្នឹង?

សុខ ៖ កាលហ្នឹងនៅពេទ្យ នៅមន្ទីរពេទ្យឃុំ ពេទ្យភូមិអីហ្នឹង ប៉ុណ្ណឹង ។

ដានី ៖ បាទ!ហើយធ្វើម៉េចទៀត?

សុខ ៖ ហើយចេះតែចេញៗ ។

ដានី ៖ ឆ្នាំណាបានចេញផុតពីផ្ទះ?

សុខ ៖ ឆ្នាំ៧៧ ចុះ៧៦ម៉ោនៅគេហៅថា ក្រូចឆ្មារ ដូចនៅស្រីស្រុកឈូកហ្នឹង នៅហ្នឹងហើយ ឡើងមកភ្នំពេញ ឡើងមកទៀតចេះតែឡើងមករហូត គេចេះតែបញ្ជូនឲ្យទៅណា មាន តែទៅហ្នឹងហើយ ។

ដានី ៖ បាទ!មុនដំបូងទៅនៅឈូកខាងក្រូចឆ្មារកំពង់ចាមហ្នឹង កាលមុនធ្វើអីគេទៅនៅហ្នឹង?

សុខ ៖ គេដាំកប្បាស!

ដានី ៖ គេដាំកប្បាស?

សុខ ៖ ចាំដាំកប្បាសដាំអីហ្នឹង!

ដានី ៖ ដាំកប្បាសគ្នាច្រើនទេ?

សុខ ៖ ប្រហែលមួយពាន់ពីពាន់ហ្នឹងមន្ទីរហ្នឹង!

ដានី ៖ ដាំកប្បាសយកទៅណា?

សុខ ៖ មិនដឹងគេយកទៅណាគេដាក់ពេញៗបាវ តែមិនបានដឹងរឿងទេចេះតែដាំ ហើយចេះ តែបេះទៅ!យើងអត់ដែលដឹងដែរ អញ្ចឹងហើយចេះតែចេញម៉ោ ចេះតែឡឹងម៉ោទៀត ទៅ ឡើងដល់ភ្នំពេញម៉ោ ។

ដានី ៖ បាទ!ឆ្នាំណាមីងមកដល់ភ្នំពេញ?

សុខ ៖ ឆ្នាំចុង៧៧ ខែប៉ុន្មានទេខ្ញុំអត់ចាំដែរ នៅពេញយូរដែរប្រហែលជា១ឆ្នាំហើយមើលទៅ ហើយគេចេះតែបញ្ជូនៗមកទៀតទៅ ។

ដានី ៖ ឆ្នាំ៧៧ហ្នឹងម៉ោធ្វើអីនៅភ្នំពេញ?

សុខ ៖ ធ្វើពេទ្យ ។

ដានី : ធ្វើពេទ្យនៅណាទៅ?

សុខ : នៅ៧៧-៧៨ហ្នឹង ពេទ្យនៅ៦មករា ពេទ្យនៅកន្លែងវះកាត់ ។

ដានី : នៅម្តុំណា?

សុខ : នៅជិតវត្តភ្នំដែរ

ដានី : ធ្វើពេទ្យកាលហ្នឹង មានបានរៀនសូត្រពេទ្យដែរឬអត់?

សុខ : រៀនអី ដូចយើងចូលចាក់ឆៅហ្នឹងកូន យើងចេះពីផ្ទះម៉ោតិចតួចអញ្ចឹង អញ្ចឹងគេរើស ដាក់ហ្នឹង ហើយយើងចេះតែចាក់ទៅ ចាក់ទៅចាក់ម៉ោគ្នាឯងម្តងម្នាក់ទៅ មានថ្នាំមើល អ្នកដាច់អ្នកមិនដាច់អីចេះតែមើលទៅ ។

ដានី : បាទ!កាលហ្នឹងព្យាបាលអីគេខ្លះ ភាគច្រើនអ្នកជំងឺម៉ោពីណា?

សុខ : មិនសូវមានគ្រុនចាញ់ទេ ច្រើនតែអ្នករបួស មានតែព្យាបាលរបួសម៉ង់ របួសទូទៅ ។

ដានី : អ្នករបួសម៉ោពីណា?

សុខ : របួសគេវៃគ្នាតាមព្រំដែនហ្នឹង គេចេះតែដឹកតាមយន្តហោះមិនដឹងពីណាពីណីយើងអត់ដឹងដែរ ។ ។

ដានី : ច្រើន?

សុខ : ច្រើនដែល រាប់ម៉ឺន មិនដឹងដឹកពីណាពីណីយើងនៅពេទ្យអញ្ចឹង នៅតែលើផ្ទះថ្ម យើងមិនដែលចុះដីណា៎ បាយអីហូបស្រាប់ ។

ដានី : កាលហ្នឹងបានបាយហូបគ្រប់គ្រាន់ទេ?

សុខ : ហ៊ឺ!បបូរកូន ម្ហូបដឹកទាំងឡានៗកន្លែងពេទ្យ កន្លែងអ្នកជំងឺអត់ខ្វះអីហូបទេ ។

ដានី : អ្ហូ!

សុខ : ផ្លែឈើអីមានពេញៗឃ្លាំង សំបូរសឹងអី ។

ដានី : សំបូរ?

សុខ : អញ្ចឹងបានថាកន្លែងណាអត់ៗទេ គេនៅចំប៉ះកន្លែងគេមានទៅគេសំបូរហូបអញ្ចឹង ។

ដានី : ពេទ្យច្រើនទេកាលហ្នឹង?

សុខ : ខ្វះអីច្រើនសឹងអី ច្រើនណាស់ ។

ដានី : សុទ្ធតែក្មេងៗស្របារៗមឹងឬក៏ចាស់មឹង?

សុខ : ចាស់ក៏មានចាស់ ក្មេងក៏មានជំនាញគេចេះឆ្លបអីជំនាញគេមានគ្រប់ជំនាញហ្នឹងណា៎ ។

ដានី : ចុះបើអ្នកគ្រប់គ្រងពេទ្យគេចាស់? អ្នកប្រធានគេនៅក្នុងហ្នឹង?

សុខ ៖ ហ្នឹងហើយប្រធានរាងចាស់ជាងគេ ។

ដានី ៖ ពីណាគេកាលហ្នឹង?

សុខ ៖ អ្នកស្រី អៀង ធិរិទ្ធ ហ្នឹង ។

ដានី ៖ អៀង ធិរិទ្ធ ហ្នឹង?

សុខ ៖ ចា៎!

ដានី ៖ គាត់អ្នកនៅពេទ្យហ្នឹង ឬក៏?

សុខ ៖ គាត់ប្រធានគ្រប់គ្រងនៅក្នុងអគ្គភាពពេទ្យ នៅកន្លែងពេទ្យខ្ញុំនៅហ្នឹង ។

ដានី ៖ ធ្លាប់ស្គាល់គាត់ដែរ អញ្ចឹងមីង?

សុខ ៖ ចុះនៅជុំគ្នាហ្នឹង ស្គាល់!

ដានី ៖ គាត់ខស្បាហ៍ចេញចូលជួបមីងអញ្ចឹងដែរ?

សុខ ៖ យើងរៀនតាមវគ្គរៀនសូត្រ រាប់រយ មិនមែនចាប់យកទៅដួលចាក់ណា៎ គេមានសក្ខាកាមគេបើករៀនច្បាស់លាស់ ថាដូចតែយើងនេះសព្វថ្ងៃនេះដែរហ្នឹង មិនមែនតែយើងចាក់ឆៅព្យាបាលមួយៗណា ។

ដានី ៖ បាទ!គាត់ឈ្មោះ អៀង ធិរិទ្ធ អញ្ចឹងកាលជំនាន់ហ្នឹង?

សុខ ៖ ចា៎!អ្នកស្រី អៀង ធិរិទ្ធ

ដានី ៖ ចុះមីងនៅពេទ្យហ្នឹង រហូតដល់ឆ្នាំណា?

សុខ ៖ ឆ្នាំ៧៨ ខ្ញុំចេញទៅទៀតហើយ នៅបានមួយឆ្នាំហ្នឹង ។

ដានី ៖ បាទ!ចេញទៅណាទៀត?

សុខ ៖ ទៅកំពតនោះ

ដានី ៖ បាទ!ទៅកំពត?

សុខ ៖ ចា៎!

ដានី ៖ ទៅធ្វើអីកំពត?

សុខ ៖ ទៅកំពតហ្នឹង គេចេះតែបញ្ជូនទៅស្រែអំបិលៗ គ្រាន់តែយើងមិនបានចេះអីអំបិលទេ ដល់ពេទ្យអញ្ចឹងគេឲ្យយើងធ្វើពេទ្យរហូតអញ្ចឹងទៅណា៎ ជំនាញចេះតិចតួចអញ្ចឹង ចេះតែជួយព្យាបាលគ។គ្នាទៅណា៎ ។

ដានី ៖ អូ!អញ្ចឹង

សុខ ៖ មានយើងទៅដល់គេឲ្យលីសែនណាអត់ទេ តែយើងជំនាញអីចេះនឹងគេរុញទៅជំនាញហ្នឹងហើយ ជួយព្យាបាលគ្នាអីចេះចុះទៅ ។

ដានី ៖ នៅស្រែអំបិលកន្លែងកំពត នៅម្តុំណា?

សុខ ៖ នៅកំពង់កណ្តាល

ដានី ៖ នៅកំពង់កណ្តាលកន្លែងធ្វើអំបិលហ្នឹង?

សុខ ៖ ចាំ!

ដានី ៖ កន្លែងធ្វើអំបិល ប៉ុន្តែមីងអត់ធ្វើអំបិលទេ តែមីងគ្រាន់តែនៅធ្វើពេទ្យនៅហ្នឹង?

សុខ ៖ ចាំ!យើងមិនចេះអី បើចុះទៅទឹកអំបិលស៊ីជើងនោះ ហើយខ្ញុំអត់ចេះជង់គេឲ្យខ្ញុំទៅខាងពេទ្យវិញទៅ ។

ដានី ៖ នៅហ្នឹងរយៈពេលប៉ុន្មានទៅ?

សុខ ៖ អត់ដល់១ឆ្នាំទេ!រត់ចេញ៧៩ហ្នឹងម៉ង យើងទៅចុង៧៨ហើយ ដល់យើងរត់៧៩ ។

ដានី ៖ រត់ទៅណាកាលហ្នឹង?

សុខ ៖ ចេះតែរត់តាមគេតាមឯង

ដានី ៖ រត់ទាំងអស់គ្នាហ្នឹងទៅ?

សុខ ៖ រត់ទាំងអស់គ្នា មនុស្សរាប់ម៉ឺនកូន មិនតិចណា មិនមែន១នាក់២នាក់ យើងរត់រាប់ម៉ឺនចេះតែទៅជាមួយគេទៅ ។

ដានី ៖ កាលហ្នឹងពេល៧៩ហ្នឹង ម៉េចបានមីងអត់ត្រឡប់ទៅផ្ទះវិញ?

សុខ ៖ កូនឯងមិនទេ!គេកុហកថាទៅជួបម៉ែឪ ដល់ទៅៗចូលព្រៃ ហើយផ្លូវទៅអត់ឃើញវង្វេងរត់ម៉ោវិញដដែល អ្នកណាមិននឹកផ្ទះ នឹកស្រុក នឹកស្រែប៉ុនរកផ្លូវទៅ វាអត់រួចយើងដូចអត់ដឹងថាទៅផ្លូវណាផ្លូវណី ចេះតែខ្វាចគ្នាចេះតែរត់ៗទៅ ។

ដានី ៖ បាទ!តាំងពីចេញពីផ្ទះម៉ោ មីងអត់ដែលទៅលេងផ្ទះទេ?

សុខ ៖ ទៅ១ដងឆ្នាំទៅកូន

ដានី ៖ អ្ហូ!ទើមទៅឆ្នាំទៅ១ដងទេ?

សុខ ៖ ចុះយើងវាអត់លុយអត់កាកអី បានទៅភ្ជុំឆ្នាំទៅខែ៩នោះ ហ្នឹងហើយបើយើងមានលុយទៅ យើងវាខ្វត់ខ្វាយដែរ ។

ដានី ៖ តាំងពីចេញពីផ្ទះម៉ោ ទើមបានទៅលេងផ្ទះ១ដងទេ?

សុខ ៖ ចាំ!វាអត់លុយ

ដានី :	អ្ហូ!យូរមែនទែន

សុខ :	ស្រុកគេទៅដល់វាផ្សេងដែល ព្រោះស្រុកគេជឿនលឿនទៅវាសម្បូរសប្បាយអញ្ចឹង ។

ដានី :	បាទ!ចុះមីងកាលហ្នឹង មីងនៅចាំថាពេលដែលយួនចូលម៉ោឆ្នាំ៧៩ហ្នឹង យើងរត់ពីស្រែអំបិល ពីកំពតហ្នឹង រត់យ៉ាងម៉េចទៅ រត់ពីកន្លែងណាទៅកន្លែងណា ហើយពេលរត់ហ្នឹងយ៉ាងម៉េចដែរ ស្ថានភាពពេលហ្នឹងយ៉ាងម៉េច?

សុខ :	ខ្ញុំរត់ឆ្លងពី គេហៅថ្នល់ជាតិលេខ៤ចេះតែឆ្លងទៅ កាត់ព្រៃម៉ោដើងអញ្ចឹងម៉ោមិនដឹងថាម៉ោណាម៉ោណី ខ្ញុំចេះតែរត់តាមគេតាមឯងទៅ ។

ដានី :	ពីណាគេជាអ្នកនាំរត់?

សុខ :	អត់ដឹងគេចេះតែទៅមុខ យើងទៅអត់ទាន់ យើងចេះតែទៅតាមគេទៅ ។

ដានី :	ចុះអ្នកក្នុងអង្គភាពស្រែអំបិលហ្នឹងទៅទាំងអស់គ្នា?

សុខ :	មានចំរុះ មានចំពោះអង្គភាពទូទាំងស្រុកហ្នឹងម៉ង ម៉ាស្រុកហ្នឹងម៉ង យើងរត់តាមប្រជាជនស្រុកគេ ព្រោះគេស្គាល់ផ្លូវ ។

ដានី :	បាទ!

សុខ :	យើងចេះតែរត់ៗទៅ ខ្លាចគ្រាប់ផ្លោងប្រជាជនចេះតែរត់ទៅ យើងមានដឹងថា បើសិនជាយើងកុំរត់យើងទៅវិញចេះចុះ មិនដឹងទេចេះតែរត់រកព្រះអាយុស ចេះតែទៅចេះតែររត់ៗអត់មានងាកក្រោយទេ ។

ដានី :	រត់អត់មានងាកក្រោយទេ?

សុខ :	ចា៎!រត់ខ្លាចអាម៍ខ្លាចេះតែរត់ទៅ

ដានី :	ពេលរត់ទៅហ្នឹងមានការពិបាកឬក៏ស្រួល ហើយការហូបចុកអីយ៉ាងម៉េចដែរ ?

សុខ :	ចេះតែដើរទៅ ហើយអង្គរមានជាប់ខ្លួនគ្រប់គ្នា ម្ហូបអាហារត្រៀមសម្រាប់ហូបតាមផ្លូវគ្រប់គ្នា ។

ដានី :	បាទ!

សុខ :	មានអង្ករម្នាក់២ៗថៃអញ្ចឹងទៅ

ដានី :	បាទ!

សុខ :	ដើរចាប់ផ្លូវយើងមានអីមានតែដើរហ្នឹង ។

ដានី :	ដើរមានសម្រាកនៅស្រុកភូមិគេដែរឬអត់?

សុខ :	ចេះតែដើរឈប់ណា សម្រាកត្រង់ហ្នឹងទៅ ថ្នល់ជាតិថ្នល់អីចេះតែសម្រាកទៅ ថ្នល់លំ

វមភូមិគេ គេដាំបាយទទួលទៅ ចេះហូបហើយ ទៅទៀតទៅ ។

ដានី ៖ បាទ!

សុខ ៖ អ្នកស្រុករត់ដែរ រត់តាមអ្នកស្រុកដែរ បើអ្នកស្រុកអត់រត់មានរត់អី ។

ដានី ៖ បាទ!រត់មកដល់ណាទៅបានឈប់១ដង មានឈប់ទេ?

សុខ ៖ យើងមិនឈប់ទេ!ដូចថាឈប់ត្រង់ណាយើងសម្រាកត្រង់ហ្នឹង

ដានី ៖ បាទ!

សុខ ៖ ហើយយើងចេះតែទៅទៀតទៅ ចេះតែដើរៗទៅទាល់តែធ្លាក់ស្រុកគេស្រុកអីអញ្ចឹង ទៅ ។

ដានី ៖ ស្រុកណាទៅ?

សុខ ៖ ស្រុកថៃ

ដានី ៖ អ្ហូ!ទៅដល់ស្រុកថៃ?

សុខ ៖ ចុះយើងមានផ្លូវឯណា ចេញពីសំឡូតទៅ យើងរត់ចូលព្រៃជ្រៅហ្នឹង ។

ដានី ៖ អ្ហូ!កាលហ្នឹងរត់មកដល់សំឡូត?

សុខ ៖ ខ្ញុំមកដល់សំឡូត ចេញពីសាលាស្រុកអាឈូនហ្នឹងចូលព្រៃ ចេះតែឆ្ងងៗជិតដល់

ដានី ៖ កន្លែងណាសាលាស្រុកអាឈូន?

សុខ ៖ ខ្ញុំចាំមិនបានទេ!ពូតែគេហៅសាលាស្រុកអាឈូនៗសំឡូត កន្លែងហ្នឹងចំណាំគេលេងរឿង នោះ ដើងភ្នំនោះ ។

ដានី ៖ បាទ!គេលេងរឿងម៉េច?

សុខ ៖ ពូគេថាលេងរឿងអ្នកកាចម៉េចទេ រឿងពីដើមហៅស្តេចឈូន ហើយគេហៅសាលាស្រុកអាឈូន មានសារគេហៅអញ្ចឹង ។

ដានី ៖ បាទ!មកដល់កន្លែងហ្នឹងយ៉ាងម៉េចទៅ?

សុខ ៖ មកដល់កន្លែងហ្នឹងសម្រាកហ្នឹង មានសំបូរថ្លៃឈើថ្លៃអីហូបនាំគ្នាហូបដេករាប់ខែនៅហ្នឹង ទៅ ដល់គេដេញនាំគ្នារត់ទៅទៀតទៅ ។

ដានី ៖ អ្នកណាគេដេញ?

សុខ ៖ ចា៎!ពូថាគ្រាប់ផ្លោងគេមកដល់ត្រង់នេះមកដល់នោះយើងចេះតែនាំគ្នារត់ទៅ ។

ដានី ៖ រត់ទៅណាទៀតទៅ?

សុខ ៖ រត់ចូលព្រៃទៀតម៉ោ ចូលម៉ោស្រុកថៃម៉ោ ។

ដានី ៖ ចូលមកដល់ស្រុកថៃ?

សុខ ៖	ដល់

ដានី ៖	ចូលមកដល់ស្រុកថៃ នៅម្តុំណា?

សុខ ៖	អត់ស្គាល់ទេ!

ដានី ៖	គេហៅអីគេស្រុកថៃពេលដែលយើងទៅហ្នឹង?

សុខ ៖	អត់ស្គាល់ច្បាស់ ចេញទៅកាលហ្នឹងដល់ក្រោយសំឡូតនោះ ថៃសំឡូតដែរ នៅម្តុំអស់ហ្នឹង ។

ដានី ៖	បាទ!ទៅនៅស្រុកថៃយូរទេ?

សុខ ៖	នៅបានប៉ុន្មានខ្ញុំចេញមកវិញដែរ មកនៅព្រំដែនយើងវិញរហូតវិញម៉ោ ។

ដានី ៖	នៅកន្លែងណាវិញ?

សុខ ៖	នេះមកនៅកន្លែងក្បាលស្ពានទឹកលិចនេះ

ដានី ៖	ក្បាលស្ពាននេះ?

សុខ ៖	ចា៎!

ដានី ៖	គេហៅអីគេអាហ្នឹងកាលពីដំបូង?

សុខ ៖	កាលហ្នឹងគេហៅភូមិដូង

ដានី ៖	ភូមិដូង?

សុខ ៖	ចា៎!

ដានី ៖	ឆ្នាំណាដែលមីងមកនៅភូមិដូងហ្នឹង?

សុខ ៖	ឆ្នាំអត់ចាំច្បាស់ទេ ឆ្នាំ៨០

ដានី ៖	ឆ្នាំ៧៩ យើងរត់

សុខ ៖	៧៩ហ្នឹងយើងរត់ទៅ មិនបានប៉ុន្មានយើងម៉ោនៅហ្នឹងវិញ ប្រហែលឆ្នាំ៩០អីហ្នឹង ឆ្នាំ៨០អីហ្នឹងឆ្នាំ៨០ ។

ដានី ៖	ឆ្នាំ៨០?

សុខ ៖	ចា៎!ឆ្នាំ៨១-៨២ មិនមែន៨១-៨២ទេ ឆ្នាំ៨០ហ្នឹង ។

ដានី ៖	បាទ!ម៉េចបានមីងមកនៅហ្នឹងវិញ?

សុខ ៖	ចុះបើមេធំៗគេហៅមកនៅហ្នឹង ក៏នាំគ្នាមកនៅហ្នឹងវិញទៅ ។

ដានី ៖	មេណាធំៗជាអ្នកហៅម៉ោ?

សុខ : នៅតាមអន្តភាព ដូចគាត់ហ្នឹងក៏នៅជាមួយខ្ញុំដែរ ហើយមេភូមិអីចេះតែនៅជុំគ្នាអញ្ចឹងទៅណា៎ ។

ដានី : អ្ហូ!អញ្ចឹង មកនៅហ្នឹងវិញមានគ្នាច្រើនទេ?

សុខ : ខ្លះមនុស្សរាប់ពាន់រាប់ម៉ឺន

ដានី : កាលមកនៅដំបូងដូចថាយ៉ាងម៉េចដែរ ដូចថាគេរៀបចំជាភូមិ ជាអីចុះក៏?

សុខ : មានផ្ទះគេ មានអីគេស្រួលបួលដាំដំណាំដំណោចអីហូបសព្វគ្រប់អញ្ចឹងទៅ ខ្លះអីហូបហើយអង្ករ ទឹកត្រីអីពេញៗឃ្លាំង ។

ដានី : អញ្ចឹង!

សុខ : មានម្ហូបអីសព្វគ្រប់ ផ្ទះធំៗ គ្រាន់តែថាវាមិនធំដូចអញ្ចឹង ផ្ទះវាព្រៃវានៅតាមជួរៗនៅតាមមាត់អូរអញ្ចឹងទៅ នៅក្រោមមាត់ហូរខ្លះទៅ ចេះតែនៅពាសវាលពាសកាលហ្នឹង

ដានី : អញ្ចឹងមានមនុស្សច្រើនដែរ?

សុខ : ច្រើនដូចតែសព្វថ្ងៃហ្នឹង គ្រាន់តែមានគេចូលបន្តិចបន្តួច មនុស្សច្រើន ។

ដានី : បាទ!ដូចម្ហូបដូចអង្ករអី បានមកពីណាម៉ោ? យើងធ្វើខ្លួនឯងឬគេបានមកពីណា?

សុខ : យើងធ្វើស្រូវបានខ្លះអញ្ចឹងទៅ អង្គការឲ្យខ្លះទៅ

ដានី : អង្គការណា?

សុខ : ដូចថា នៅតាមឃ្លាំងគេមិនបើ យើងបើហូប សម័យហ្នឹង ខៀវ សំផន នៅហើយថៃគេជំនួយអីអញ្ចឹង!

ដានី : បាទ!

សុខ : ហើយយើងចេះតែចែកគ្នាហូបអញ្ចឹងទៅ ។

ដានី : បាទ!កាលហ្នឹង ខៀវ សំផន គាត់នៅហ្នឹង?

សុខ : នៅហ្នឹង នៅប៉ុនគាត់ មានអីអង្ករម៉ោញ៉ុកៗឃ្លាំងហូបមិនអស់ផង ។

ដានី : អង្ករហូបអត់អស់ទេ?

សុខ : មិនខ្វះទេ!អង្ករច្រើនណាស់ ។

ដានី : ចុះម្ហូបមានអ្វីខ្លះ?

សុខ : មានសព្វគ្រប់ហ្នឹង សំបូរអីហូបណាស់

ដានី : សំបូរអីហូបកាលហ្នឹង?

សុខ : ចា៎!សំបូណាស់មិនអត់ទេ គ្រាន់តែគ្មានចាយលុយអី សំបូររបស់ដូចឥឡូវអត់ទេ

ដានី ៖ បាទ!អញ្ចឹងផ្ទះនៅតាមមាត់ស្ទឹង?

សុខ ៖ ផ្ទះដូចសព្វថ្ងៃហ្នឹងអញ្ចឹង គ្រាន់តែពីមុនគេធ្វើផ្ទះតូច ឥឡូវគេធ្វើផ្ទះធំៗ នៅអញ្ចឹង នៅម្តុំអស់ហ្នឹង ហ្នឹងសុទ្ធតែផ្ទះគេចាស់ហើយហ្នឹង ។

ដានី ៖ អញ្ចឹង!

សុខ ៖ ផ្ទះគេនៅពីដើម

ដានី ៖ ប៉ុន្តែកាលហ្នឹងមានភូមិមានអីស្រឡះអញ្ចឹង ឬក៏ព្រៃ?

សុខ ៖ គេកាប់ៗស្រឡះ ពេលយើងមកដល់វាមិនទាន់ទូសទ្រាយបានភ្លាមទេ ទាល់តែយើងនៅបានយូរទៅទើបយើងទូសទ្រាយនៅទៅ នៅធ្វើស្រែបានសីងអីហ្នឹង ។

ដានី ៖ បាទ!ចុះដំបូងកាលហ្នឹងអើយ?

សុខ ៖ យើងម៉ោភ្លាម យើងមិនទាន់បានកាប់ព្រៃកាប់អីធ្វើស្រែ ធ្វើចំការអីទេ យើងហូបរបស់ដែលគេខបត្តមឲ្យអញ្ចឹងទៅ ចែកគ្នាហូបទៅ សំបូរអីហូបដែរ ព្រោះយើងគ្នាមិនច្រើនប៉ុន្មាន វាជំនួយម៉ោសមនឹងបានហូបគ្រប់គ្រាន់ ។

ដានី ៖ កាលហ្នឹងមីងម៉ោធ្វើអី ពេលដែលមីងមកនៅដំបូង?

សុខ ៖ មានធ្វើអី គ្រាន់តែគេឲ្យដឹកជញ្ជូនគៀនហ្នឹងទៅ ។

ដានី ៖ ដឹកជញ្ជូនឲ្យពីណា?

សុខ ៖ ឲ្យតាម៉ុក ខ្មែរក្រហមហ្នឹង

ដានី ៖ យកទៅឲ្យកងទ័ព?

សុខ ៖ កងទ័ព

ដានី ៖ ចុះកងទ័ពនៅណា?

សុខ ៖ កងទ័ពនៅជួរនុខទៀត នៅដូចនៅភ្នំយាយសំអញ្ចឹងនៅឆ្ងាយៗ នៅតាគង់នៅអីអញ្ចឹង ទៅហើយប្រជាជននៅហ្នឹងត្រៀបត្រាទៅ ដូចតែយើងធម្មតាអញ្ចឹង បើសមរភូមិនៅ ទល់នោះនេះមិនមែនសមរភូមិណា ប្រជាជនកកើតធម្មតាហ្នឹង មានទៅពិបាកអី ។

ដានី ៖ បាទ!អត់ពិបាកអីទេ

សុខ ៖ វាមានជួបខបសគ្គខ្លះៗទៅ វាស្រួលខ្លះអញ្ចឹងទៅ វាមិនពិបាកទាំងអស់ណា បើវាពិបាកទាំងអស់ងាប់អស់ហើយ មិនមានសាច់ឈាមដូចសព្វថ្ងៃនេះទេ ងាប់មនុស្សអស់ហើយបើថាលំបាកលំបិនងាប់អស់ហើយ ។

ដានី ៖ បាទ!ធ្វើអីបានខ្លះ ដូចថាយើងដាំដំនាំអីខ្លះ?

សុខ ៖ យើងច្រើនដាំស្រូវវាកើតឆ្នាំហ្នឹង យើងនៅយើងកាប់មួយស្រែៗ

ដានី ៖ ដាំស្រូវ?

សុខ ៖ ដាំស្រូវ ស្ទូង ដក ចុះយើងនៅជិតព្រំដែនដែរ នៅជិតថៃដែរ យើងមានពូជមានការ យើងស្គាល់គ្នា រាប់គ្នាធម្មតាដូចតែយើងសព្វថ្ងៃនេះអញ្ចឹង ។

ដានី ៖ បាទ!

សុខ ៖ រាប់អានគ្នាទៅ អានេះហុចពូជនេះ ហុចពូជនោះ យកមកបន្តរបង្កើតដាំអញ្ចឹងទៅ កន្លែងខ្លះក៏គ្នាយ៉ាប់ទៅ ប៉ះកន្លែងខ្លះក៏គេស្រួលអញ្ចឹងទៅណា៎ ដូចផ្ទះខ្លះលំបាក ផ្ទះខ្លះអត់លំបាកអញ្ចឹង ប្រៀបទៅអញ្ចឹងទៅ ។

ដានី ៖ បាទ! ចុះកាលហ្នឹងមីងរៀបការឬនៅ?

សុខ ៖ ខ្ញុំរៀបការឆ្នាំ៩០ទេ

ដានី ៖ រៀបការឆ្នាំ៩០ទេ?

សុខ ៖ ចា៎!ការឆ្នាំ៩០អ៊ុន តាក់ ចូលនេះ

ដានី ៖ កាលនោះមីងអាយុប៉ុន្មានកាលឆ្នាំ៨០ជាងហ្នឹង?

សុខ ៖ មិនដឹងអាយុប៉ុន្មានទេ ឥឡូវ៥៣ហើយ មិនដឹងដកស្រេងនៅសល់ប៉ុន្មានទេ

ដានី ៖ អ៊ូ!ដល់ពេលឆ្នាំ៩០នេះបានមីងរៀបការ?

សុខ ៖ ចា៎!បានរៀបការ មានគ្រួសារទៅ ។

ដានី ៖ ចុះមីងតាំងពីមីងចូលមកនៅហ្នឹងនៅហ្នឹងរហូតឬក៏មានផ្លាស់ប្តូរអីទៀត?

សុខ ៖ អត់ទេ!នៅនឹងស្រុកនឹងម៉ង អត់មានដើរទៅលិចទៅកើតទេ ទៅស្រុកនេះស្រុកនោះទេ

ដានី ៖ អញ្ចឹងបានន័យថា ពេលដែលឆ្នាំ៨០យើងម៉ោនៅ ពេលហ្នឹងយើងនៅតាមមាត់អូរ នៅតាមអីអញ្ចឹង ហើយក្រោយម៉ោដូចជាមានសង្គ្រាមអីទៅ ធ្វើឲ្យមីងផ្លាស់ទៅនៅដីថៃទៀត ហីក៏អត់មានទេនៅហ្នឹងរហូត?

សុខ ៖ ទៅ១ដងឆ្នាំ៨៥ ដល់ហើយត្រឡប់មកនៅកន្លែងដើមវិញ ។

ដានី ៖ ដល់ឆ្នាំ៨៥ហ្នឹងយ៉ាងម៉េចមីង?

សុខ ៖ ឆ្នាំ៨៥ហ្នឹង ខាងក្នុងគេមិនរុលម៉ោ រុលម៉ោខាងនេះមិននាំគ្នារត់ អន្តុយស្ងៀមៗស្រាប់តែគ្រាប់ផ្លោងវ៉ូតៗពីប៉ៃប៉ែតម៉ោ នាំគ្នារត់ទៅ ចេះតែរត់ៗ ដល់ថៃឃើញក៏ដឹកយកទៅដាក់នៅជំរុំមួយទៅ ។

ដានី ៖ ជំរុំហ្នឹងគេហៅជំរុំអីទៅកាលហ្នឹង?

សុខ :	ជំរុំ៨៥ យើងរត់ឆ្នាំ៨៥ គេដាក់ជំរុំ៨៥ដែរទៅ ។

ដានី :	អ្នកដែលរស់នៅសំឡូតហ្នឹង រត់ទៅនៅហ្នឹងទាំងអស់គ្នា ឬក៏មានជំរុំណាផ្សេងទៀត?

សុខ :	បែកគ្នាទៅផ្សេងៗគ្នា ណានៅនេះណានៅនោះខ្ញុំអត់ដឹងដែរ នឹងវាបែកខ្ញែកគ្រប់កន្លែង អញ្ចឹង តាមក្តុំៗនៅរៀងៗខ្លួន ។

ដានី :	បាទ!ជំរុំ៨៥ហ្នឹង នៅម្តុំណា?

សុខ :	នៅខាងក្រោយនេះ ក្រោយបឹងត្រកួននេះ មិនដឹងត្រង់ណាទេ អត់ចាំបានទេ ។

ដានី :	ស្រុកថៃ គេហៅអីគេកន្លែងហ្នឹង?

សុខ :	ខ្ញុំមិនដឹងហៅអីទេ!អត់ចាំ អត់ដឹងថាគេហៅឈ្មោះភូមិអីទេ អត់ចាំទេ

ដានី :	នៅហ្នឹងនៅដីថៃ នៅក្នុងជំរុំហ្នឹងគេធ្វើអីខ្លះទៅ?

សុខ :	នៅដល់ហ្នឹងមានចំការគេ ស្រុកថៃគេធ្វើចំការអត់អស់ណាក៎កូន ទៅដាំស្រូវ ដាំពោត ដាំដំឡូងអីនៅកៀនៗគេហ្នឹង ។

ដានី :	គេឲ្យដាំដែរ?

សុខ :	មានអី!គេឲ្យដាំ ដាំសម្រាប់តែយើងហូប មានចិញ្ចឹមត្រី មានល្ពៅ មានបន្លែបន្ការដូច យើងនៅផ្ទះយើងអញ្ចឹង ។

ដានី :	បាទ!គេឲ្យយើងដាំយើងហូបខ្លួនឯងទៅ?

សុខ :	យើងហូបខ្លួនយើង អ្នកណាប៉ុនដាំអ្នកនោះបានហូបហើយ ។

ដានី :	បាទ!ចុះគេមានបើកសម្ភារៈអីឲ្យខ្លះទេ នៅហ្នឹង នៅក្នុងជំរុំ៨៥ហ្នឹង?

សុខ :	ខាងជំនួយគេមាន អង្ករ ត្រីខ ប៊ិចចេង អំបិល ប្រហុក ស្ករអីហ្នឹងគេបើកឲ្យម៉ាចប់ ហើយ ។

ដានី :	នៅហ្នឹងរយៈពេលប៉ុន្មានទៅ?

សុខ :	មិនដឹងនៅបានប៉ុន្មានទេ គ្មានចាំទេពូ តាំងពីម៉ោហ្នឹងម៉ោ មិនសូវចងចាំទេ រវល់តែ លំបាកលំបិនមិនបានចងចាំទេ ។

ដានី :	បាទ!ហើយឆ្នាំណាបានមកនៅកន្លែងហ្នឹងវិញ?

សុខ :	មិនដឹងឆ្នាំប៉ុន្មានទេនេះ មិនចាំច្បាស់ទេ ម៉ោវិញម៉ោយូរដែរហើយ ។

ដានី :	ម៉ោយូរដែរហើយ?

សុខ :	ចា៎!តាំងពីយើងម៉ោរហូត យើងផ្កាច់ខ្លួនត្រូវគ្នាម៉ោ

ដានី :	បាទ!ពេលដែលម៉ោវិញហ្នឹងយ៉ាងម៉េចដែរ ទិដ្ឋភាពនៅកន្លែងហ្នឹង?

សុខ ៖ ម៉ោវិញគ្រាន់តែថា ផ្ទះយើងពេលទៅមិនស្រឡះ ម៉ោវិញព្រៃដុះជិត ហើយយើងត្រូវកាយនៅសារថ្មីអញ្ចឹងទៅ ខ្លះកប់នេះកប់នោះកាយយកទុកប្រើវិញទៅ គេចេញទៅគេកប់របស់របរដល់ម៉ោវិញគេកាយ ។

ដានី ៖ បាទ!ចុះម៉េចខុសប្លែកដូចកាលពីយើងទៅផ្ទះយើងយ៉ាងម៉េច ហើយពេលដែលយើងត្រឡប់មកវិញវាយ៉ាងម៉េចដែរ វាពិបាកអីឬក៏យ៉ាងម៉េច?

សុខ ៖ រឿងពិបាកៗវាពិបាកហើយ ព្រៃដុះជិតទៅហើយ ដើមឈើធំៗដែរ ។

ដានី ៖ បាទ!មានតែព្រៃទេ មានតែដើមឈើទេ?

សុខ ៖ មានព្រៃដុះលិចផ្ទះអញ្ចឹងទៅ ។

ដានី ៖ ហើយម៉េចទៀត?

សុខ ៖ ហើយយើងនាំគ្នាវែកកកើតនៅទៅ ។

ដានី ៖ ចុហអត់មានមីន មានអីទេ?

សុខ ៖ មានមីន!ប៉ុន្តែអាខ្លះគេរាវទៅ អាខ្លះវាមានដោយកន្លែង វាមានទុំៗអញ្ចឹង វាមែនទៅដាក់អីពាសវាលទាំងអស់អត់ទេ ។

ដានី ៖ បាទ!ពីណាគេជាអ្នកដាក់?

សុខ ៖ ចំរុះមិនដឹងពីណាពីណីទេ!ប្រជាជនមិនសូវដឹងដែរ ។

ដានី ៖ ចុះមីនយើង ដូចថាខាងកងទ័ពខ្មែរក្រហមយើងជាអ្នកដាក់ ឬក៏កងទ័ពខាង?

សុខ ៖ ខាងនោះជាអ្នកដាក់

ដានី ៖ ខាងណា?

សុខ ៖ ខាងគេចូលម៉ោហ្នឹង

ដានី ៖ ខាងយួន ខាង?

សុខ ៖ ចា៎!ហ្នឹងហើយ គេដាក់ទៅ ដូចកន្លែងយើងនៅអីគេដាក់អញ្ចឹងណា៎ យើងធ្លាប់នៅយើងមានដាក់ឯណា យើងដាក់ឲ្យឆ្ងាយៗពីស្រុកពីភូមិទៅ យើងមានដាក់ជិតណា៎ ។

ដានី ៖ បាទ!ចុះមីនអញ្ចឹងធ្វើម៉េចទៅ យើងម៉ោវិញ?

សុខ ៖ យើងម៉ោ អ្នកចេះរាវឲ្យគេរាវគេអីវែកនៅទៅ ។

ដានី ៖ បាទ!ចុះមានគ្រោះថ្នាក់អីដោយសារមីនដែរឬអត់?

សុខ ៖ មានដោយខ្លះមិនអត់ទេ!

ដានី ៖ មានដែរ?

សុខ ៖ បន្ទាប់នៅកប់នឹងដីយើងដើរដាន់ យើងដែលមើលឃើញអស់អី ដើរវាមានប៉ះពារខ្លះ ហើយវាមិនមែនទៅច្រើនទេ វាមានជាតែអ្នកប្រហើនទេ ប្រហើននឹងអាហ្នឹងវាងាប់ នឹងអាហ្នឹង ។

ដានី ៖ បាទ!

សុខ ៖ បើអ្នកគេប្រយ័ត្នគេអត់មានទេ បើអញ្ចឹងគេងាប់អស់ហើយ ។

ដានី ៖ អ្ហូ!អញ្ចឹង

សុខ ៖ យើងគិតតែប៉ុណ្ណឹង បើអ្នកប្រហើននឹងអំពើហ្នឹង វាទទួលនូវអំពើហ្នឹង បើគេប្រយ័ត្នប្រដាវាមិនអីទេ ។

ដានី ៖ បាទ!ចុះដល់ពេលមីងមកវិញម៉ោនៅផ្ទះដដែលវិញ?

សុខ ៖ ម៉ោវិញយើងរុសរើផ្ទះហ្នឹងធ្វើសារថ្មីទៅ

ដានី ៖ ធ្វើនៅណា?

សុខ ៖ ធ្វើនៅកន្លែងផ្ទះចាស់ដដែលហ្នឹង យើងរាវៗទៅ បើមិនមានអី ចេះតែនាំគ្នាឈូសឆាយនៅទៅ ធ្វើផ្ទះនៅទៅ ដល់សព្វថ្ងៃនេះក៏អត់មានអី គេម៉ោក៏មិនស្គាល់ណារាប់ឡានដាក់ដែរ ស្រុកព្រៃច្រើនអញ្ចឹងនោះ ស្គាល់បានតិចតួចដាក់ហ្នឹង វាមិនដែលដាក់ខាសពេញដីទេ ។

ដានី ៖ បាទ!

សុខ ៖ ដូច្នេះមានប្រឡោះពេលគេរស់នៅហើយ គេបង្កើតការរស់នៅ ។

ដានី ៖ បាទ!ចុះកាលហ្នឹងមីងនៅម្នាក់ឯងទេ?

សុខ ៖ នៅជាមួយបងប្អូន

ដានី ៖ បងប្អូនណា?

សុខ ៖ បងប្អូនដូចថារត់ៗម៉ោហ្នឹងអ្នកណាគេចិត្តល្អយើងនៅ មានដូចថាយើងរាប់អានគ្នាអញ្ចឹង

ដានី ៖ បាទ!

សុខ ៖ យើងនៅជាមួយគ្នាទៅ ជួយយកអាសារគ្នាទៅ រាប់គ្នាទៅដូចជាបងប្អូនបង្កើតអញ្ចឹង

ដានី ៖ បាទ!

សុខ ៖ នៅជិតៗគ្នា ឈឺស្កាត់អីចេះៗតែជួយមើលគ្នាអញ្ចឹងទៅ នៅជុំៗគ្នាទៅ ។

ដានី ៖ បានប៉ុន្មាននាក់កាលហ្នឹង?

សុខ ៖ ខ្ញុំម្នាក់ឯងនៅជាមួយគេ ។

ដានី ៖ ជាមួយគេ គេណា?

សុខ : គេហ្នឹង ចាំមើលកូនក្មួយខ្ញុំ៣នាក់ ខ្ញុំ៤នាក់ ឪខ្ញុំទៀត៥នាក់ ៥-៦នាក់ ។

ដានី : អូ!មួយផ្ទះហ្នឹងនៅ៥-៦នាក់?

សុខ : ចាំ!ធម្មតាៗមានអីដូចតែយើង

ដានី : ចុះមីងដល់ពេលម៉ោកាលហ្នឹង យើងនៅហ្នឹងយើងធ្វើអីទៅ?

សុខ : នៅហ្នឹងយើងចេះតែរុសហើយ ធ្វើស្រែចំការហ្នឹងកូន ធ្វើស្រូវធ្វើអី យើងចេះតែនាំគ្នាធ្វើទៅ ។

ដានី : បាទ!ធ្វើនៅណា ធ្វើស្រូវធ្វើស្រែ?

សុខ : នេះម៉ោវាល ចេញម៉ោមានស្រែមានអីកាប់គាស់ដាំទៅ វាមិនដែលមានមីនណាពេញទឹកពេញដីនោះ មានមីនកន្លែងត្រង់ថាឈរមុខដាក់គ្នានោះទេ ។

ដានី : ហើយចុះដូចថាកាលហ្នឹង មានឈ្មោះភូមិ ឈ្មោះឃុំអីពិតប្រាកដឬមិនទាន់មានឈ្មោះឲ្យគេហៅឈ្មោះភូមិ ឃុំអីទេ?

សុខ : មានកាលហ្នឹងគេហៅអន្លង់ភាពទេ ។

ដានី : អន្លង់ភាពម៉េចទៅ?

សុខ : ចាំ!ដូចគេហៅអន្លង់ភាពពួក១១២ ពួក៨៥ គេដាក់សារឲ្យអញ្ចឹង

ដានី : បាទ!

សុខ : គេមិនមែនថាអានេះភូមិដូង ភូមិដូងជាគោលភូមិដូង នៅនោះបន្ទាយទី២ អាហ្នឹងសារគេអញ្ចឹង ។

ដានី : បាទ!

សុខ : អាហឹងភូមិគេ ហើយអាហ្នឹង ដូចភូមិខ្ញុំនៅភូមិដូងហៅភូមិដូង ដាក់សារឲ្យគ្នា បើទៅចំភូមិវាលហាតអញ្ចឹងគេហៅវាលហាតទៅ អាហ្នឹងឯងមានភូមិដូចតែសព្វថ្ងៃអញ្ចឹង ។

ដានី : បាទ!

សុខ : សព្វថ្ងៃក៏មានភូមិដែរ តែឥឡូវគេបំបែក វាមានភូមិកណ្តាល ភូមិក្បាលស្ពានគេបំបែកជាភូមិ កាលមុនភូមិមានតែមួយ ។

ដានី : មានតែភូមិដូងមួយទេ?

សុខ : ចាំ!មានតែភូមិដូងមួយជាគោល ដូចគេហៅស្រុកភូមិដូងអញ្ចឹង ។

ដានី : បាទ!ហើយក្រោយម៉ោបានគេបំបែក?

សុខ : គេបំបែក ដល់យើងត្រូវគ្នាអញ្ចឹងគេបំបែក តាមភូមិ

ដានី ៖ ឆ្នាំណាគេបំបែកហ្នឹង?

សុខ ៖ ឆ្នាំយើងផ្តាច់ខ្លួនហ្នឹង មិនដឹងឆ្នាំប៉ុន្មានទេ!

ដានី ៖ ឆ្នាំ៩៦?

សុខ ៖ ចាំ!

ដានី ៖ ម៉េចបានគេដាក់ឈ្មោះភូមិកណ្តាល ភូមិក្បាលស្ពាន?

សុខ ៖ ដាហ្នឹងយើងប្រជាជនច្រើន យើងបំបែកដូចថាស្រួលដាក់វេនទៅវត្ត ហ៎ខាងភូមិនេះ អញ្ចឹងទៅស្រួល បើយើងច្រើនគ្រប់គ្រងវាអត់គ្រប់ ។

ដានី ៖ បាទ!

សុខ ៖ វាអត់បានជិតដល់ ដល់ហើយបានមានភូមិកណ្តាល ភូមិក្បាលស្ពាន ។

ដានី ៖ ចុះម៉េចបានគេដាក់ឈ្មោះថាភូមិកណ្តាល?

សុខ ៖ មេភូមិគេ មិនដឹងម៉េចដាក់

ដានី ៖ ចុះភូមិក្បាលស្ពាន?

សុខ ៖ ភូមិក្បាលស្ពាននោះកន្លែងស្ពានលិចនោះ

ដានី ៖ ហេតុអីបានគេដាក់ភូមិ?

សុខ ៖ វាមានវ័ណ្ណថ្នល់អញ្ចឹង ដូចខាងនេះខាងកើតថ្នល់ដាក់ភូមិកណ្តាលអញ្ចឹងទៅ ខាងលិចផ្លូវ ភូមិក្បាលស្ពានអញ្ចឹងទៅ ។

ដានី ៖ បាទ!ម៉េចបានគេដាក់ឈ្មោះអញ្ចឹង ឬក៏មានឈ្មោះអញ្ចឹងយូរហើយ ដូចភូមិវាលហាត ភូមិ?

សុខ ៖ អាហ្នឹងមានតាំងពីដើម

ដានី ៖ ដូចភូមិតាសីជ្រុំ?

សុខ ៖ អាហ្នឹងមានតាំងពីដើមម៉ោ ហើយកន្លែងហ្នឹងអញ្ចឹងគេដាក់ទៅបណ្តោយ ហើយមានគេ នៅរហូតមក ។

ដានី ៖ ពីអន្តាលទៅ ពីដើមម៉ោ ?

សុខ ៖ ពី៧៩នោះ យើងចំណាំគេនិយាយទៅ យើងចេះតែតៗគ្នាអញ្ចឹងទៅ អូរស្រឡៅៗ បន្ទាយទី២នៅជាប់បន្ទាយទី២ទល់ផ្លូវនឹង ។

ដានី ៖ បាទ!ចុះពីមុន៧៩អត់មានទេ អត់មានឈ្មោះហ្នឹងទេ?

សុខ ៖ អត់ទេ!ដល់ពេលយើងនៅទៅ ដល់មានយើងដើរទៅចេះតែដាក់ផាវទៅ ។

ដានី ៖ អូ!អញ្ចឹង

សុខ ៖ ចា៎!

ដានី ៖ យើងដាក់ខ្លួនយើង?

សុខ ៖ ខ្លួនយើង យើងនៅចេះតែហៅត្រង់នេះចេះ ត្រង់នោះចុះ ។

ដានី ៖ បាទ!ដាក់អញ្ចឹង ចុះមីងដឹងថាម៉ាឡៃកាលពីមុនម៉ោនៅ កន្លែងហ្នឹងយ៉ាងម៉េចដែរ? កាលមុន៧៩ដែលយើងម៉ោនៅកន្លែងហ្នឹង?

សុខ ៖ វាពិបាកៗហើយកូនអើយ នៅពីដើមនោះ ។

ដានី ៖ ប៉ុនកន្លែងហ្នឹងមានមនុស្សរស់នៅទេ កាលពីមុនម៉ោ?

សុខ ៖ មានតាំងពី៧៩នោះ ។

ដានី ៖ ពីមុន៧៩មានដែរឬអត់?

សុខ ៖ ពីមុនខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំរត់មកទាន់ត្រឹម៧៩ យើងដឹងតែយើងជាន់នៅដីហ្នឹង៧៩ ។

ដានី ៖ ចុះមីងមកនៅ ក្រោយម៉ោរយៈពេលប៉ុន្មានឆ្នាំបានមីងការ?

សុខ ៖ នៅយូរដែរ នៅនេះរហូត

ដានី ៖ បាទ!ពេលណាបានមីងរៀបការជាមួយពូ?

សុខ ៖ ឆ្នាំ៩០ កាលនោះយើងនៅលីវទេ ឥឡូវយើងគិតថាយកគ្រួសារធ្វើអី បើស្រុកគេម៉េះៗហ្នឹង កុំឲ្យពិបាកដល់ក្មេង ពិបាកតែយើងម្នាក់បានហើយ យើងស្រួលវេចរត់ ។

ដានី ៖ បាទ!កាលហ្នឹងមីងអាយុប៉ុន្មាន កាលមីងរៀបការឆ្នាំ៩០?

សុខ ៖ មិនដឹងប៉ុន្មានទេ អាយុ៥៣ទូទាត់ទៅនៅសល់ប៉ុន្មាន ។

ដានី ៖ បាទ!ចុះពូគាត់ធ្វើអីដែរ?

សុខ ៖ ឪវាបើមែនទែនគ្រូ ព្រោះគាត់នៅរៀនរហូត

ដានី ៖ រៀននៅណា?

សុខ ៖ រៀននៅភ្នំពេញ រៀននៅអី ដើររៀនតាមជំរុំ គាត់ដើរតែរៀនទេ រៀនប្រឡងបាក់ឌុបកាលឆ្នាំ៩០ដែរ ។

ដានី ៖ បាទ!ហើយចុះមុនការហ្នឹងគាត់មកនៅហ្នឹងដែរឬអត់ទេ?

សុខ ៖ ម៉ោនៅ

ដានី ៖ គាត់ធ្វើអីម៉ោនៅហ្នឹង?

សុខ ៖ គាត់គ្មានធ្វើអី គាត់នៅផ្ទះដូចប្រជាជនធម្មតាអញ្ចឹង ។

ដានី ៖ គាត់អត់មានធ្វើកងទ័ពទេ?

សុខ ៖ អត់ទេ!គាត់មានធ្វើអីគាត់ គាត់នៅតែផ្ទះជាមួយប្រពន្ធកូនហ្នឹង ។

ដានី ៖ មុនហ្នឹង មុនគាត់ការ?

សុខ ៖ មុនការក៏គាត់នៅតែផ្ទះដែរ អត់មានធ្វើអីទេ នៅតែរៀន

ដានី ៖ រៀននៅណា?

សុខ ៖ រៀននៅជំរុំតាឡឹក គេហៅជំរុំតាឡឹកនោះ គាត់រៀនរហូត រៀនបារាំង រៀនអង់គ្លេស រៀនភាសា ។

ដានី ៖ គាត់ចេះអង់គ្លេស ចេះបារាំងដែរ?

សុខ ៖ ចេះ ប៉ុនឥឡូវបែបភ្លេចអស់ហើយ បើយូរដែរ

ដានី ៖ អញ្ចឹងគាត់អ្នកស្រុកណាដែរ?

សុខ ៖ គាត់អ្នកស្រុកតាកែវ

ដានី ៖ នៅតាកែវនៅស្រុកណា?

សុខ ៖ គេហៅវត្តអីវីទ្ធៗ មិនដឹងម៉េចទេ!

ដានី ៖ ចុះមីងធ្លាប់ទៅទេ?

សុខ ៖ ខ្ញុំអត់ មិនដែលបានទៅទេ ស្រុកឯងបានទៅតែម្តងយូរហើយ ល្មមស្រុកនោះ យើងអត់ខ្សត់ខ្សោយ យើងពិបាកដែល ។

ដានី ៖ អញ្ចឹងបន្ទាប់ពីការហើយធ្វើអីទៀតទៅ?

សុខ ៖ មានធ្វើអីទេ!រកស៊ីតិកតក់ៗទៅ

ដានី ៖ ពូអត់មានធ្វើទាហានអីទេ?

សុខ ៖ អត់ទេ!

ដានី ៖ ការយ៉ាងម៉េច កាលហ្នឹងការរបៀប?

សុខ ៖ ការដូចយើងនេះអញ្ចឹង មានអាចារ្យ មានភ្លេង មានជូនអីធម្មតាហ្នឹង ។

ដានី ៖ ចុះបងប្អូនមីងនៅស្រុកអត់ដឹងទេ ពេលដែលមីងរៀបការ?

សុខ ៖ អត់ទេ!អត់មានដឹងទេ យើងការនៅនេះ មានតុមានភ្លេង មានភ្ញៀវថៃម៉ោគគ្រឹកគ្រេងទៅណា ម៉ាសប្បាយរបស់គេដែរ ។

ដានី ៖ ចុះពេលមាហរណកម្មហើយឆ្នាំ៩៦ យ៉ាងម៉េចដែរ ដូចថាមីងចាប់ផ្តើមដូចថា?

សុខ ៖ ជាអាជីបរបស់ពីដើមម៉ោម៉េច យើងនៅតែរកស៊ីតិកតក់ៗចិញ្ចឹមខ្លួនតែប៉ុណ្ណឹង ។

ដានី ៖ បាទ!

សុខ ៖ អត់មានទៅហក់លោតរកអីៗណា

ដានី ៖ ចុះមីងមានដីនឹងគេដែលឬអត់?

សុខ ៖ ខ្ញុំមានតែដីមីនហ្នឹងអត់មានរាវទេ ព្រោះយើងមិនសូវចេះធ្វើស្រែផង ។

ដានី ៖ អត់ចេះធ្វើស្រែទេ?

សុខ ៖ ព្រោះយើងតាំងពីតូចម៉ោ វាមិនដែលបានស្ទូងបានដក ។

ដានី ៖ ចុះមីងឥឡូវអត់មានដីស្រែទេ?

សុខ ៖ អត់ទេ!អត់មានទេ

ដានី ៖ អត់មានដីទេអញ្ចឹង?

សុខ ៖ ដីមីនហ្នឹង បើយើងទៅទ្រូសទ្រាយវាអស់ យើងអត់លុយផងក៏លក់ទៅបាត់ទៅ ។

ដានី ៖ លក់ទៅបាត់ទៅ?

សុខ ៖ ចា៎!នៅគេឯងទៅ គ្រាន់តែវាមិនស៊ាប់ ហើយវាតិកតក់ទៅ គ្រាន់តែវាចិញ្ចឹមឆ្នាំង

ដានី ៖ ធ្វើអីខ្លះទៅបើវាពិតប្រាកដ និយាយឲ្យចំ?

សុខ ៖ ពិតប្រាកដយើងរកនេះបរិលនោះទៅ ចេះតែរកទៅ

ដានី ៖ ចុះមីងបើតាមមីងគិតមើល តើក្រោយពីយើងផ្លាចខ្លួន យើងសមាហរណកម្មចូលម៉ោ ហ្នឹង ហើយកាលពីមុនចូលម៉ោមួយណាស្រួលជាង?

សុខ ៖ ទេ!ឥឡូវវាស្រួលហើយ វាស្រួលហួសពីស្រួលហើយ យើងបើសិទ្ធដើរលេងដល់ណាក៏ បានឲ្យតែយើងមានលុយ ។

ដានី ៖ បាទ!

សុខ ៖ ហើយមានផ្លូវដើរ មានសាលា វាសប្បូរសប្បាយ វាហួសហើយ វាហួសពីសង្គមទៅ ទៀត ខ្ញុំស្គាល់ពីសង្គមច្បាស់ វាសប្បូរសប្បាយជាងសង្គម កាលជំនាន់សម្តេច វាលើសពីសម្តេចទៅទៀតហើយ ។

ដានី ៖ បាទ!

សុខ ៖ ដូច្នេះយើងមិនអាច ប្រៀបនិយាយបានទេ បើខ្ញុំទាន់ពីសង្គម ទាន់សម័យកសាងហ្នឹង

ដានី ៖ បាទ!

សុខ ៖ ទាន់សម័យនេះទៀត ៣ជំនាន់ហើយដែលខ្ញុំទាន់ច្បាស់នេះ

ដានី ៖ បាទ!

សុខ : ដូចនេះពីសង្គមមកឥឡូវ ឥឡូវវាលើសពីសង្គម៣-៤ដងហើយ ស្រុកគេវាទំនើប ហើយមានសាលារៀន មានភ្លើងមានអីបើកសព្វគ្រប់ មានទូរទស្សន៍ មានទូរស័ព្ទអីនិយាយឆ្លងគ្រប់ប្រទេសហើយ ។

ដានី : បាទ!ចុះពូគាត់ធ្វើអីដែរសព្វថ្ងៃ?

សុខ : អត់មានធ្វើទេ នៅតែផ្ទះ

ដានី : នៅតែផ្ទះទេ គាត់អត់មានធ្វើការអីទេ?

សុខ : ចា៎!

ដានី : ចុះមីងទើបបានទៅលេងផ្ទះឆ្នាំទៅនេះទេ?

សុខ : ចា៎!

ដានី : បែកប៉ុន្មានឆ្នាំទៅ បានមីងទៅ?

សុខ : យូរដែរហើយខ្ញុំ មិនដឹងប៉ុន្មានទេ រាប់ភ្លេចមុខ ភ្លេចក្រោយ ។

ដានី : ម៉េចបានយូរហើយទើបទៅលេងផ្ទះ?

សុខ : វាអត់បច្ច័យទៅហ្នឹង អត់បច្ច័យផ្ទះម៉េចបានទៅ ទាល់តែយើងមានបច្ច័យ ។

ដានី : បាទ!ចុះខាងបងប្អូនមីងនៅស្រុកនោះ គាត់មានដែលធ្លាប់មកលេងមីងនៅស្រុកដែរឬអត់?

សុខ : ម៉ោម្នាក់ ពៅគេ អាប្រុស

ដានី : ម៉ោឆ្នាំណា?

សុខ : ម៉ោរាល់តែឆ្នាំដែរ មួយឆ្នាំវាម៉ោលេងមួយដងទៅ វាដើរវែងម្នាក់ហ្នឹង គ្រាន់ខស្បាហ៍ម៉ោអើតបងឈឺ ។

ដានី : ចុះមីងខ្ញុំចង់ដឹងពីអារម្មណ៍របស់មីង នៅពេលដែលមីងទៅលេងផ្ទះលើកទី១បន្ទាប់ពីបែកទៅយូរ ដូចថាតាំងពីចេញម៉ោ៣០ឆ្នាំជាងហើយ ដំបូងមីងមានអារម្មណ៍យ៉ាងម៉េចដែរពេលដល់ផ្ទះដំបូងដូចថា អារម្មណ៍វា?

សុខ : ប្លែកអត់ស្គាល់ផ្ទះ ដូចថាកន្លែងកន្ទុកកន្ទៀនអីមើលអត់ស្គាល់ អត់ដឹងមើលអត់ស្គាល់បងប្អូនក៏មើលអត់ស្គាល់ដែរ ។

ដានី : អត់ស្គាល់បងប្អូន?

សុខ : អត់ទេ!អត់ស្គាល់ទេ មិនម៉ោកុហកភូតភរ អត់ចាំផ្ទះ ផ្ទះយើងធ្វើសារថ្មី ភូមិករគេ

កកើតសារថ្មី ហើយដើមឈើគេដាំឡើងប៉ុនៗណាណី ហើយយើងម៉េចចាំបាន ទីវត្តអារាមដែលយើងធ្លាប់ទៅហ្នឹងក៏យើងចាំមិនបាន អត់មមានស្គាល់ទេ ៗ

ដានី ៖ បងប្អូនក៏អត់មានស្គាល់ដែរ?

សុខ ៖ អត់ទេ!

ដានី ៖ បងប្អូនស្គាល់មីងដែរឬអត់?

សុខ ៖ គេឃើញ គេស្គាល់តាមរូបថតដែលយកទៅហ្នឹង

ដានី ៖ បាទ!ស្គាល់តាមរូបថត?

សុខ ៖ តែឃើញមុខ ហើយស្រដៀងៗចាំ

ដានី ៖ កាលហ្នឹងមីងទៅ មីងបានជួបមុខឪពុកមីងដែរ?

សុខ ៖ បានជួប១ដង ឆ្នាំ៩០គាត់មកលេង ៗ

ដានី ៖ គាត់មកលេង?

សុខ ៖ ជំនាន់ អ៊ុន គាក់ គាត់មកលេងបាន៣-៤ថ្ងៃគាត់ទៅវិញ គាត់ស្លាប់ទៅ ៗ

ដានី ៖ គាត់មកលេងមីងបាន១ដងដែរ?

សុខ ៖ ចា៎!លេងនៅជិតខ្លួនរាប់នោះ

ដានី ៖ បើម្ដាយមីងអត់ទេ?

សុខ ៖ អត់ទេ!មិនដឹងគាត់ខូចតាំងពីអង្គាល់ ខ្ញុំចេញម៉ោគាត់នៅក្មេង ៗ

ដានី ៖ ចុះមីង អារម្មណ៍មីងយ៉ាងម៉េចដែរ នៅពេលដែលមីងទៅឃើញផ្ទះ មានអីប្លែក?

សុខ ៖ មើលទៅវាស្រណោចស្រណោះ វាគន្ធងគន្លោចណាស់មើលទៅ វាកណ្ដោចកណ្ដោង ព្រោះយើងបែកស្រុកទេសយូរឆ្នាំហើយ ដល់ទៅឃើញបងប្អូនចាស់ៗទៀត ខ្ញុំម៉ោតាំងពីខ្ញុំនៅក្មេងៗមិនទាន់ស្លៀកខោជិត ហើយទៅវិញមានកូន អាខ្លះបាក់ធ្មេញអស់អញ្ចឹងទៅ ៗ

ដានី ៖ អូ!អញ្ចឹង

សុខ ៖ អញ្ចឹងវាលំបាកលំបិនដែរ វាស្រណោះស្រុកទេសមិនដែលបានទៅ រត់ៗគ្មានរាក ក្រោយ ៗ

ដានី ៖ ចុះអ្នកជិតខាងមិត្តភក្រ្តមីងកាលពីក្មេងៗនៅក្នុងភូមិអីម៉េចដែរ?

សុខ ៖ អត់!ទៅអត់មានជួប

ដានី ៖ អត់មានជួបទេ?

សុខ :	ចា៎!គេចាស់ៗហើយ គេមានប្ដីមានសីទៅនៅតាមប្ដីនៅស្រុកឆ្ងាយៗអស់ហើយ ខ្លះក៏ទៅរកស៊ីនៅស្រុកគេអញ្ចឹងទៅ ។

ដានី :	ចុះមីងដូចថាយើងបែកយូរ កាលពីកេងយើងនៅជាមួយឪពុកម្ដាយ ជាមួយបងប្អូន ដូចថាមានអារម្មណ៍ស្និតស្នាលជាមួយគ្នាអញ្ចឹង ដល់ពេលមីងបែកយូរ ហើយទៅវិញ ដូចថាអារម្មណ៍ស្និតស្នាលហ្នឹងវានៅ មានដដែលឬក៏វាខុសប្លែកពីមុន?

សុខ :	ចិត្តគំនិតកូនអ្នកល្អទៅ វាចេះតែនៅនឹកឃើញបងប្អូនមីងមារ មានចិត្តយើងមិនរាប់រក គ្នាអី ។

ដានី :	បាទ!អត់ទេគ្រាន់តែថាយើង ដូចថាមីងធ្លាប់នៅនេះ?

សុខ :	វាកណ្ដោចកណ្ដែង គ្រាន់តែឃើញគ្នាទៅ វាកណ្ដោចកណ្ដែងហ្នឹងណា៎ វាបែកគ្នាយូរ ហ្នឹងគ្រាន់តែអោបគ្នាយំទេ គ្មានពាក្យអីនិយាយវែងឆ្ងាយទេ វាមែនទែនគេស្រណោះ ដូចខ្ញុំបែកស្រុកយូរឆ្នាំគេស្មានថាស្លាប់អញ្ចឹង ។

ដានី :	បាទ!

សុខ :	ហើយបងប្អូនចេះតែមកអោបយំៗហើយ យំគ្រប់គ្នាទៅ ម៉ោរោមដូចអីអញ្ចឹង ។

ដានី :	បាទ!ហើយមួយទៀតខ្ញុំចង់ដឹងពីអារម្មណ៍មីង ដូចថាមីងធ្លាប់រស់នៅនេះយូរដែរ ដូចថាមានការរាប់អានពីអ្នកម៉ោពីផ្សេងៗគ្នា ម៉ោនៅនេះជាមួយគ្នា តស៊ូកំសត់កំរជាមួយគ្នា មានការរាប់អានគ្នា មានអារម្មណ៍ស្និតស្នាលអីអញ្ចឹង ហើយចំពោះនៅស្រុកវិញ មីងបែកយូរដូចថាកាលពីក្មេងៗរស់នៅហ្នឹង ស្និតស្នាលជាមួយបងប្អូន ជាមួយអ្នកភូមិ ដូចថាការសិតស្នាលហ្នឹងវាខុសពីមុនដែរ?

សុខ :	ចា៎!ខុស ទៅវិញភ្លេចអត់ស្គាល់គេ ។

ដានី :	អញ្ចឹងមីងភ្លេចអត់ស្គាល់គេទេ?

សុខ :	អត់!អត់ចាំទេ ទោះបីឥឡូវយើងនៅជុំគ្នាអញ្ចឹង បែកតែ៤-៥ឆ្នាំទៅភ្លេចគ្នាទៀត ហើយការចងចាំដូចវាចាំមិនបាន ។

ដានី :	បាទ!ចុះមីងទៅលេងផ្ទះបានប៉ុន្មានថ្ងៃ?

សុខ :	ខ្ញុំទៅបាន៣ថ្ងៃ ខែភ្ជុំហើយ ខ្ញុំម៉ោវិញ

ដានី :	ចុះមីងទៅនោះនឹកនេះដែរឬអត់?

សុខ :	នឹក!ដូចតែនេះស្រុកកំណើតអញ្ចឹង ហើយនោះស្រុកកំណើតដែលអញ្ចឹង ប៉ុនយើងធ្លាប់នៅនេះ នឹកនេះជាងហើយ យើងធ្លាប់ថានៅស្រុកស្រែមានបន្ទន់ណាបត់ដែបត់ដើង

បត់តាមវាលស្រែកូនចៅវាអត់ចេះបត់ ដល់អញ្ចឹងកូនចៅវាចេះតែទាមកផ្ទះវិញ ។

ដានី : បាទ!

សុខ : នៅផ្ទះយើងមានបន្តន់បត់ដែបត់ដើងស្រួលបួលអញ្ចឹងទៅ ស្រុកស្រែមានណាយើងទៅបត់នៅតាមភ្លឺស្រែហ្នឹង មានអីអនាម័យស្រួលបួល ។

ដានី : បាទ!

សុខ : អញ្ចឹងនៅមិនបានយូរទេ!នៅបានប៉ុន្មានថ្ងៃ ម៉ោវិញម៉ោ

ដានី : មីងបានទៅផ្ទះតែ១ដងហ្នឹងទេ?

សុខ : តែមួយដងហ្នឹង មិនដែលបានទៅទៀតទេ ព្រោះនឹកឃើញថាឪពុកម្ដាយស្លាប់អត់ ហើយនៅប្អូនៗ ហើយនៅបែកគ្នាទៀត ហើយយើងក៏មិនសូវមានលុយកាក់ចុះឡើង ដែរជួបតាមទូរស័ព្ទតិចតួចទៅ ។

ដានី : បាទ!ចុះខាងប្ដីមីង ក៏មីងអត់ដែលទៅដែល?

សុខ : អត់មានទៅទេ ព្រោះម៉ែក្មេកមកនៅនេះអស់ហើយ ។

ដានី : អ្ហូ!មកនៅនេះអស់ហើយ?

សុខ : ចា៎!យើងមិនដឹងទៅធ្វើអី បើគាត់មកនៅនេះអស់ហើយ

ដានី : បាទ!

សុខ : ចា៎!យើងមិនបាច់ទៅនាំតែអស់សោហ៊ុយធ្វើអី បើគាត់បើមកនៅនេះទៅហើយ

ដានី : បាទ!

សុខ : សន្សំលុយតិចតួចឲ្យគាត់ទៅនៅជិតនេះ

ដានី : បាទ!ចុះមីង កាលពីមីងម៉ោតាមផ្លូវអី មីងធ្លាប់ជួបអ្នកដែលពិបាកវេទនា ឈឺឆ្អាត់តាម ផ្លូវយើងឲ្យអង្ករ ឲ្យបាយទឹកអី?

សុខ : ជួយឲ្យថ្នាំដង្ហូវឲ្យអី ឲ្យអីហូបអញ្ចឹងទៅ ដូចថាគ្នាទីទ័ល អត់អញ្ចឹង យើងមានយើងចេះជួយគ្នាទៅ យើងអាណិត យើងអ្នកមានចិត្តធម៌ ។

ដានី : អញ្ចឹង!គ្នាឯងឬអ្នកដំណើរ?

សុខ : ទោះបីមិនស្គាល់គ្នា ក៏ឲ្យដែរ ឲ្យតែអ្នកដំណើរជាមួយគ្នា ឃើញគេលំបាកលំបិនចេះតែជួយគ្នាទៅណា៎ ។

ដានី : ជួយដែរ កាលហ្នឹងមីងជួយដែរ?

សុខ : ជួយ មិនថាអ្ហូចេះមើលរំលងអីអត់ទេ ដូចថាយើងក្រុមពេទ្យអី ឃើញគេសម្រាលកូន

នៅនឹងផ្លូវអញ្ជឹង សម្រាលកូនចោលអញ្ជឹង ខ្ញុំលើកបីយកទៅឲ្យអញ្ជឹងទៅ អត់មានថា អ្វី ចិត្តអាក្រក់អីចេះចុះអត់ទេ យើងចេះជួយគ្នា បីកូនយកទៅ ឲ្យថ្នាំសង្កូវ ចាក់ថ្នាំ អីឲ្យទៅ ។

ដានី : ចាក់ថ្នាំចាក់អីឲ្យដែរ?

សុខ : ចា៎!ព្រោះយើងមានថ្នាំស្ពាយជាប់នឹងខ្លួនរហូត យើងមានអត់ណា៎ ថ្នាំពេញៗសម្ពាយ នឹង ស្ពាយទៅដល់កន្លែងណា អ្នកណាគ្រុនក្តៅអី ឲ្យថ្នាំលេបសិនទៅ ចេះតែជួយៗគ្នា រហូត បើយើងធ្វើល្អ បានល្អហើយកូន ។

ដានី : បាទ!ចុះជំនាន់៣ឆ្នាំ មីងមានដែលជួយពីណាប្អុអត់?

សុខ : សម័យ៣ឆ្នាំ យើងពេទ្យហើយ យើងសម្រាប់តែចែកចាយវិញហើយ ។

ដានី : បាទ!

សុខ : ចា៎!យើងមិនមែននេះទេ យើងសម្រាប់ចែកចាយវិញហើយ គេមករកយើងចែកឲ្យគេ ទៅ ចែកថ្នាំតាមស្រែណាគេស្ទូង គេឈឺចែកឲ្យទៅ ដើរចែកតាមមក្ខីស្រែ តាមគេ ស្ទូង តាមគេច្រូតអញ្ជឹងទៅ ។

ដានី : បាទ!ចុះកាលសម័យ៣ឆ្នាំ មីងមានដែលទៅផ្ទះទេ?

សុខ : ទៅ៧/៧១ដង បាន១ថ្ងៃ ។

ដានី : ទៅលេងផ្ទះឆ្នាំ៧/៧១ដង?

សុខ : ចា៎!បាន១ថ្ងៃ ទៅលេងមានអីធម្មតា តែចាស់ៗគាត់នៅបាយរួម

ដានី : បាទ!

សុខ : ខ្ញុំម៉ោហ្នឹងមិនទាន់បាយរួមទេ នៅហូបបាយតាមផ្ទះ ដល់ខ្ញុំទៅលេងឃើញបាយរួម ទៅបាន១ថ្ងៃម៉ោវិញ នៅជុំគ្នាសុទ្ធតែក្មេងៗមានតឹកឃើញលំបាកលំបិនអី សុទ្ធតែវ សប្បាយទាំងអស់គ្នា ព្រោះជុំគ្នាច្រើននោះ ។

ដានី : បាទ!

សុខ : ហើយក្មេងមានដឹងអំពីចេះគិតដូចសព្វថ្ងៃណា ។

ដានី : បាទ!

សុខ : គេទាញចូលរុណក្តាម ចេះតែចូលគេទៅ ។

ដានី : បាទ!ចុះមីងឥឡូវហ្នឹងមីងមានដែលព្រួ មានដែលបានស្តាប់ពីពត៌មានទាក់ទងពីតុលាការ ដែលគេកាត់ទោសមេដឹកនាំខ្មែរក្រហមប្អុអត់?

សុខ : ខ្ញុំអត់ដែលស្តាប់ទេ!

ដានី : អត់ដែលបានតាមដានអីទេ?

សុខ : អត់ទេ!ខ្ញុំអត់មានពេលទេ ខ្ញុំអត់ចង់ស្តាប់ទេខ្ញុំខ្ជិលណាស់

ដានី : ម៉េចអញ្ចឹង?

សុខ : វាការងាររកំប៉ិកកំប៉ុក មិនមានពេលអីទៅស្តាប់អញ្ចឹងទេ ឮតែគេនិយាយហើយ ក៏ហី ទៅ ខ្ញុំក៏មិនបានចាប់ទុកក្នុងគំនិតទេ ។

ដានី : បាទ!ចុះមីងអត់ចាប់អារម្មណ៍ថាកាត់ទោសហ្នឹង យ៉ាងម៉េចៗទេ?

សុខ : គ្រាន់តែថាយើងធ្វើខុសគេកាត់ទោសទៅ ខ្ញុំគ្រាន់តែគិតខ្លួនឯងប៉ុណ្ណឹង ថាយើងធ្វើខុស ដឹកនាំខុស អាហ្នឹងស្រេចតែគេវិនិច្ឆ័យទៅ អាហ្នឹងខ្ញុំអត់ដឹងទេ ។

ដានី : មីងគិតថា កាលជំនាន់ហ្នឹង ពួកគាត់ដឹកនាំខុសដែរ?

សុខ : ចុះឥឡូវយើង ខ្ញុំពិបាកថាណាស់កូន បើខ្ញុំលនិយាយថាចេះទៅវាចុះ ព្រោះខ្ញុំនៅចំ កន្លែងស្រួល វាមិនដឹងពិបាកនិយាយថាម៉េច បើនិយាយថា ដូចតែខ្ញុំនៅផ្ទះហ្នឹងមាន បាយហូបគ្រប់ ហើយនៅផ្ទះនោះអត់មានបាយហូប ចង់និយាយអញ្ចឹង ចង់និយាយ តែប៉ុណ្ណឹងទេ កូនឯងយល់ហើយ ។

ដានី : បាទ!

សុខ : ដូចខ្ញុំនៅផ្ទះហ្នឹង បាយហូបគ្រប់ ចំណីហូបគ្រប់គ្រាន់ ហើយផ្ទះនោះអត់មានអីហូបទេ ។

ដានី : បាទ!

សុខ : ដូចថាសកម្មភាពនីមួយៗយើងវាមិនដឹងទេ ខ្ញុំវានៅចំកន្លែងមន្ទីរ ហើយយើងវាអត់ យ៉ាប់ ត្រង់ថាយើងពេទ្យអញ្ចឹង យើងមានហូបគ្រប់គ្រាន់ មានថ្នាំសង្កូវគ្រប់អញ្ចឹងទៅ យើងមានទៅលីសែងឯណាយប់អាធ្រាត យើងអត់ ដូច្នេះយើងមិនបានដឹងរឿងគេ ម៉េចៗទេ ។

ដានី : បាទ!អញ្ចឹងខ្ញុំអរគុណមីងច្រើន ដែលចំណាយពេលឲ្យខ្ញុំជួបសួរនាំទាក់ទងពី ជីវិតរបស់ មីង ។

សុខ : ចា៎!

ដានី : បាទ!ខ្ញុំអរគុណ ។

«ចប់»